

# សង្ខេបស្តីពីថវិកាជាតិឆ្នាំ២០២០

ទិដ្ឋភាពទូទៅនៃសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០២០ ដើម្បីគាំទ្រដល់សមាជិកសភា
ក្នុងដំណើរការអនុម័ត

**វិទ្យាស្ថានសភាកម្ពុជា** | ខែធ្នូ ឆ្នាំ២០១៩

រក្សាសិទ្ធិដោយ©២០១៩

រក្សាសិទ្ធិគ្រប់យ៉ាង។ ការស្រាវជ្រាវនេះ ឬផ្នែកណាខ្លះនៃរបាយការណ៍នេះមិនអាចយកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតិពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

បោះពុម្ពដោយព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ៖ https://senate.gov.kh/

# សង្ខេបថវិកាជាតិឆ្នាំ២០២០

# មាតិកា


អំពីរបាយការណ៍ ....................................................... 1

សេចក្តីសង្ខេបប្រតិបត្តិ ....................................................... 1

ក្របខណ្ឌផែនការសេដ្ឋកិច្ច ....................................................... 5

ការសន្មតផែនការសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ....................................................... 5

ការវាយតម្លៃភាពសមហេតុផល ....................................................... 6

ការវាយតម្លៃហានិភ័យសេដ្ឋកិច្ច ....................................................... 7

ទស្សនវិស័យសារពើពន្ធ ....................................................... 9

ចំណូលថវិកា ....................................................... 9

ក្របខណ្ឌផែនការ ....................................................... 9

ចំណាយថវិកា ....................................................... 10

ក្របខណ្ឌផែនការៈ វិភាជន៍តាមមូលដ្ឋានសេដ្ឋកិច្ច ....................................................... 10

ក្របខណ្ឌផែនការៈ វិភាជន៍តាមមុខងារ និងក្រសួង ....................................................... 11

រដ្ឋបាលថ្នាក់ក្រោមជាតិ ....................................................... 13

តុល្យភាពថវិកា និងហិរញ្ញវត្ថុ ....................................................... 15

តុល្យភាពថវិកា ....................................................... 15

គម្រោងកម្ចី និងបំណុល ....................................................... 15

ហានិភ័យចំពោះទស្សនវិស័យសារពើពន្ធ ....................................................... 16

ការវិភាគដើម្បីជួយគាំទ្រដល់សមាជិកសភា ....................................................... 17

ជម្រើសនៃសេណារីយ៉ូ (ការសន្មត) ក្នុងការធ្វើផែនការ ....................................................... 17

ការប្រែប្រួលនៃថវិកាពាក់ព័ន្ធនឹងការសន្មតលើកំណើនចំណាយសម្រាប់បន្ទុកបុគ្គលិក ....................................................... 17

ថវិកាកែសម្រួល(ផែនការតាមសេណារីយ៉ូអព្យាក្រឹត) ....................................................... 18

ការប្រៀបធៀបទៅនឹងប្រទេសដែលជាសមាជិកអាស៊ានដទៃទៀត ....................................................... 19

ចំនុចពិភាក្សាបន្ថែមមួយចំនួន សម្រាប់សមាជិកសភា ....................................................... 20

ឯកសារយោង ....................................................... 21

ឧបសម្ព័ន្ធ ....................................................... 22

## អំពីរបាយការណ៍

របាយការណ៍សង្ខេបអំពីទិដ្ឋភាពទូទៅនៃថវិកា ត្រូវបានរៀបចំឡើងដោយមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះជាលំហាត់អនុវត្តន៍មួយនៃកម្មវិធីបណ្តុះបណ្តាលដែលមានគោលបំណងផ្តល់នូវព័ត៌មានបន្ថែមអំពីផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនដល់គណៈកម្មការរបស់សភា ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីថវិកាជាតិឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល។ របាយការណ៍នេះពិពណ៌នានូវផែនការរបស់រាជរដ្ឋាភិបាល និងផ្តល់នូវការវិភាគផ្សេងៗពីមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពីស្ថាប័នអន្តរជាតិនានា ដូចជាធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានមន្ត្រីស្រាវជ្រាវមួយក្រុមតូច ដែលនៅមានកម្រិតនៅឡើយក្នុងការទទួលបានភ្លាមៗនូវទិន្នន័យផ្នែកសេដ្ឋកិច្ច និងសារពើពន្ធជាក់ស្តែង និងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល។ សមាជិកសភា និងអ្នកពាក់ព័ន្ធដទៃទៀតគួរបន្តពឹងផ្អែកលើព័ត៌មានជាផ្លូវការរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងរៀបចំផែនការ។ របាយការណ៍នេះមានគោលបំណងត្រឹមប្រមូលផ្តុំនូវចំណុចគោល និងការវិភាគបន្ថែម ដើម្បីកំណត់នូវផ្នែកសំខាន់នានានៃគោលនយោបាយសារពើពន្ធ ដែលសមាជិកសភាអាចយកចិត្តទុកដាក់បន្ថែមទៀត។

# សេចក្តីសង្ខេបប្រតិបត្តិ

## សង្ខេបផែនការថវិកា

រាជរដ្ឋាភិបាលរំពឹងថាចំណូលថវិកាសរុបក្នុងឆ្នាំ ២០២០ នឹងកើនឡើង ២១,៨% ធៀបទៅនឹងថវិកាឆ្នាំ ២០១៩ ដែលកំណើននេះ រួមចំណែកធំដោយកំណើនអាករពិសេស ៣៨,៦% និងកំណើនពន្ធប្រយោល ២៤,៩% (តារាង ៩-១)។ ពន្ធលើប្រាក់ចំណូល ត្រូវបានរំពឹងថានឹងកើនឡើង ១៧,៣% ពន្ធលើពាណិជ្ជកម្មក្រៅប្រទេសកើន ១៤,៩% និងចំណូលមិនមែនសារពើពន្ធរំពឹងថានឹងកើនឡើង ៣,៥%។

ចំណាយថវិកាសរុបដែលបានគ្រោងនៅឆ្នាំ២០២០ ត្រូវបានកើនឡើង ២០,៧% ធៀបទៅនឹងថវិកាឆ្នាំ ២០១៩ ដែលភាគច្រើនជំរុញដោយការវិនិយោគមូលធន ដែលកើនឡើង ៤៦%។ ចំណាយចរន្ត ត្រូវបានគ្រោងនឹងកើនឡើង ៧,២% ធៀបនឹងថវិកាឆ្នាំ ២០១៩ ដែលមួយផ្នែកនៃកំណើននេះឆ្លុះបញ្ចាំងអំពីផែនការរបស់រាជរដ្ឋាភិបាលក្នុងការតម្លើងបៀវត្សក្នុងវិស័យសាធារណៈ ដោយកើនប្រមាណ៨,៦%។

ជារួម រាជរដ្ឋាភិបាលរំពឹងថាឱនភាពថវិកាសរុបនឹងមានចំនួន ៧ ០០៤ ប៊ីលានរៀល ស្មើនឹង ៥,៩% នៃ ផ.ស.ស ដែលកើនឡើងពី ៥ ៩៧៨ប៊ីលានរៀលនៅឆ្នាំ២០១៩។ ទោះយ៉ាងណា អតិរេកចរន្ត ត្រូវបានគេរំពឹងថានឹងកើនឡើងថែមទៀតដល់ ៥ ៨៦២ ប៊ីលានរៀលនៅឆ្នាំ ២០២០ ពីចំនួន ២ ៧៦៧ប៊ីលានរៀល ក្នុងឆ្នាំ ២០១៩។ ចំណុចនេះឆ្លុះបញ្ចាំងឱ្យឃើញថា ការខ្ចីប្រាក់បន្ថែម នឹងប្រើប្រាស់ជាមូលធនវិនិយោគ កាន់តែច្រើនជាងមុន។

តារាង-S1៖ សង្ខេបផែនការថវិកា ឆ្នាំ២០២០ ធៀបនឹងឆ្នាំកន្លងទៅ (គិតជាប៊ីលានរៀល)

| | អនុវត្តន៍ | | | ច្បាប់ | | កំណើន | កំណើនជាមធ្យម |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | 2020 | 2016-19 |
| **ចំណូល**[1] | | | | | | | |
| ពន្ធលើប្រាក់ចំណូល | 2,953 | 3,798 | 4,059 | 4,330 | 5,080 | 17.3% | 15.8% |
| ពន្ធប្រយោល | 4,189 | 4,936 | 5,729 | 5,902 | 7,373 | 24.9% | 15.1% |
| អាករពិសេស | 2,955 | 3,676 | 4,969 | 4,137 | 5,734 | 38.6% | 19.0% |
| ពន្ធលើពាណិជ្ជកម្មអន្តរជាតិ | 2,010 | 1,977 | 2,371 | 2,411 | 2,769 | 14.9% | 7.0% |
| ចំណូលពន្ធផ្សេងៗ | 91 | 133 | 168 | 100 | 135 | 35.7% | 16.2% |
| ចំណូលមិនមែនសារពើពន្ធ | 2,080 | 2,446 | 2,851 | 2,714 | 2,808 | 3.5% | 16.2% |
| ចំណូលមូលធន | 120 | 142 | 195 | 193 | 193 | 0.1% | 10.7% |
| **ចំណូលសរុប** | 14,398 | 17,108 | 20,342 | 19,787 | 24,092 | 21.8% | |
| **ចំណាយ** | | | | | | | |
| ចំណាយបៀវត្ស | 5,506 | 6,839 | 8,001 | 7,863 | 8,540 | 9% | 14% |
| ការទិញទំនិញ | 1,300 | 1,408 | 1,529 | | | | |
| សេវាកម្ម | 1,357 | 1,582 | 1,687 | | | | |
| អត្ថប្រយោជន៍សង្គម | 973 | 1,087 | 1,336 | | | | |
| ឧបត្ថម្ភធន | 1,018 | 1,381 | 1,349 | | | | |
| ចំណាយផ្សេងៗ | 299 | 452 | 472 | | | | |
| បន្ទុកហិរញ្ញវត្ថុ (ចំណាយការប្រាក់នៃបំណុល) | 335 | 342 | 387 | 525 | 542 | 3% | 21% |
| ចំណាយចរន្ត | 10,876 | 13,237 | 14,973 | 16,827 | 18,037 | 7% | 15% |
| ចំណាយមូលធន | 6,051 | 6,779 | 7,579 | 8,938 | 13,059 | 46% | 19% |
| **ចំណាយសរុប** | 16,928 | 20,016 | 22,551 | 25,765 | 31,096 | 21% | 16% |
| **តុល្យភាពថវិកាចរន្ត** | 3,402 | 3,729 | 5,174 | 2,767 | 5,862 | 112% | 24.2% |
| **តុល្យភាពសរុប** | (2,530) | (2,908) | (2,209) | (5,978) | (7,004) | 17.1% | 37.8% |
| **បំណុលសាធារណៈ (%ផ.ស.ស)** | 22.5 | 22.8 | 21.5 | 21.3 | | | |

*ប្រភព៖សេចក្តីព្រាងច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០២០[1, 2, 3]*

## វិធានការថ្មី

ដើម្បីធានានូវសង្គតភាពរវាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ រាជរដ្ឋាភិបាលបានស្នើនូវវិធានការពន្ធដារ និងចំណាយ ក៏ដូចជាផែនការនៃការធ្វើវិសោធនកម្ម មួយចំនួនដែលរួមមាន៖

- បៀវត្សជាប់ពន្ធ៖ ធ្វើវិសោធនកម្មមាត្រា ៤៧ ថ្មី (II) នៃច្បាប់ពន្ធដារ ដើម្បីតម្លើងបៀវត្សជាប់ពន្ធអប្បបរមា ពី ១ ២០០ ០០០ រៀល ទៅ ១ ៣០០ ០០០ រៀល សម្រាប់ឆ្នាំ ២០២០។

[1] ចំណូលក្នុងស្រុកសរុបសុទ្ធ

- ការពិន័យចំពោះការបង់យឺតៈ ធ្វើវិសោធនកម្មមាត្រា ១៣១ និងមាត្រា ១៣២ នៃច្បាប់ពន្ធ ដើម្បីបន្ថយអត្រាពន្ធ ពី ២% ទៅ ១,៥% ចំពោះរូបវន្តបុគ្គល ឬសហគ្រាស ដែលយឺតយ៉ាវក្នុងការបង់ពន្ធ។
- បទប្បញ្ញត្តិពន្ធតែមប្រ៊ីៈ ធ្វើការផ្ទេរពន្ធតែមប្រ៊ីដែលជាគុណប្រយោជន៍ថវិកាថ្នាក់ជាតិ ទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី/ខេត្ត ចាប់ពីឆ្នាំ២០២០ ។
- ចំណាយលើបៀវត្សសាធារណៈៈ បង្កើនបៀវត្សមូលដ្ឋាន ៦,៨% នៅឆ្នាំ ២០២០ ដែលកំណើននេះធ្លាក់ចុះពី ១០%នៅក្នុងថវិកាឆ្នាំ ២០១៩ និង១២%នៅក្នុងថវិកាឆ្នាំ ២០១៨។
- វិត្ថារកម្មកញ្ចប់ចំណាយៈ កញ្ចប់អន្តរាគមន៍ថ្មីត្រូវបានស្នើសម្រាប់ការឧបត្ថម្ភធនបន្ថែមសម្រាប់ការចំណាយវិនិយោគឃុំ សង្កាត់។ កញ្ចប់នេះស្មើនឹង ១% នៃចំណូលចរន្តថវិកាជាតិ។

## ផែនការចំណាយ តាមកម្មវិធី/វិស័យ

វិស័យសន្តិសុខ និងការពារជាតិ មានកំណើនចំណាយថវិកាខ្ពស់ ឈានដល់ ៤ ៦៦០ ប៊ីលានរៀលនៅឆ្នាំ ២០២០ កើនឡើង ៩,៣% បើប្រៀបធៀបទៅនឹងថវិកាឆ្នាំ ២០១៩។ បន្ទាប់គឺវិស័យសង្គមកិច្ចមានកំណើន ៨,៩% (តារាង ន-២)។ ចំណាយថវិកាវិស័យសេដ្ឋកិច្ចមានកំណើនយឺតជាងគេ ដែលនឹងកើនឡើងតែ ៣,៣% ។

តារាង-ន២ៈ ចំណាយចរន្តថ្នាក់ជាតិតាមវិស័យសំខាន់ៗ (គិតជាប៊ីលានរៀល)

| វិស័យ | | អនុវត្តន៍ | | ថវិកា | | កំណើន | កំណើនជាមធ្យម |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | 2020 | 2016-19 |
| វិស័យរដ្ឋបាលទូទៅ | 1,885 | 2,536 | 2,471 | 2,246 | 2,351 | 4.7% | 10.8% |
| វិស័យការពារជាតិ និងសន្តិសុខ | 2,859 | 3,405 | 3,989 | 4,264 | 4,660 | 9.3% | 16.2% |
| វិស័យសង្គមកិច្ច | 4,007 | 4,841 | 5,756 | 6,197 | 6,748 | 8.9% | 15.0% |
| វិស័យសេដ្ឋកិច្ច | 1,141 | 1,323 | 1,387 | 1,507 | 1,557 | 3.3% | 9.2% |
| ចំណាយមិនទាន់មានមុខសញ្ញា | 984 | 1,132 | 1,368 | 2,614 | 2,721 | 4.1% | 26.5% |

*ប្រភពៈ* ច្បាប់ទូទាត់ថវិកាជាតិឆ្នាំ២០១៦-២០១៨ និងច្បាប់ថវិកាជាតិឆ្នាំ២០១៩-*២០២០*

## ក្រសួង ស្ថាប័នដែលមានកំណើនចំណាយខ្ពស់ជាងគេចំនួន ០៥ និងទាបជាងគេចំនួន ០៥

តារាងន -៣ ខាងក្រោម បង្ហាញថា ក្រសួងធនធានរ៉ែ និងថាមពល នឹងទទួលបានកំណើននៃការចំណាយខ្ពស់បំផុតគឺ ៣១% ធៀបនឹងថវិកាឆ្នាំ ២០១៩ បន្ទាប់មកគឺក្រុមប្រឹក្សាធម្មនុញ្ញ មានកំណើន ១៩%។

ថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងថយចុះខ្លាំងបំផុតសម្រាប់ឆ្នាំ ២០២០ គឺធ្លាក់ចុះ ១៨,៣% ធៀបនឹងថវិកាឆ្នាំ ២០១៩ បន្ទាប់មកក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលនឹងថយចុះ ១៦% ធៀបនឹងឆ្នាំមុន។

តារាង-ទ៣៖ ក្រសួង ស្ថាប័នដែលមានកំណើនចំណាយខ្ពស់ជាងគេចំនួន០៥ និងទាបជាងគេចំនួន០៥

| ចំណាយចរន្តដោយក្រសួង ស្ថាប័ន | ចំណាយចរន្ត (គិតជាប៊ីលានរៀល) | | | | | | កំណើន |
|---|---|---|---|---|---|---|---|
| | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2019-2020 |
| ក្រសួងរ៉ែ និងថាមពល | 21 | 28 | 49 | 42 | 57 | 74 | 30.8% |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 8 | 8 | 11 | 12 | 12 | 14 | 18.9% |
| ក្រសួងមហាផ្ទៃ (រដ្ឋបាលទូទៅ) | 1,325 | 1,151 | 1,391 | 1,635 | 1,697 | 1,959 | 15.4% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 600 | 687 | 797 | 902 | 993 | 1,137 | 14.5% |
| ក្រសួងមុខងារសាធារណៈ | 28 | 35 | 43 | 51 | 54 | 61 | 14.4% |
| ព្រឹទ្ធសភា | 57 | 60 | 65 | 76 | 87 | 87 | 0.1% |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 334 | 379 | 387 | 386 | 409 | 407 | -0.6% |
| ក្រសួងពាណិជ្ជកម្ម | 117 | 121 | 133 | 152 | 148 | 126 | -14.6% |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 90 | 111 | 148 | 165 | 163 | 137 | -15.8% |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 11 | 88 | 156 | 186 | 79 | 65 | -18.3% |

*ប្រភព៖* ច្បាប់ទូទាត់ថវិកាជាតិឆ្នាំ២០១៦-២០១៨ និងច្បាប់ថវិកាជាតិឆ្នាំ២០១៩-*២០២០*

## ហានិភ័យនិង បញ្ហាសម្រាប់ការពិចារណាបន្ថែម

ទោះបីជាថវិការបស់ប្រទេសកម្ពុជាស្ថិតក្នុងជំហររឹងមាំក៏ដោយ បញ្ហាដូចមានរៀបរាប់ខាងក្រោមអាចជះឥទ្ធិពលដល់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងគួរទទួលបានការត្រួតពិនិត្យយ៉ាងដិតដល់ (ក្នុងចំណោមបញ្ហាផ្សេងទៀតនៅក្នុងរបាយការណ៍ដែលមានជាបន្តបន្ទាប់)៖

- **កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងភាពមិនប្រាកដប្រជាផ្នែកពាណិជ្ជកម្ម៖** ប្រទេសកម្ពុជា ប្រឈមនឹងការគំរាមកំហែងជាច្រើនចំពោះការនាំចេញ និងចំណូលដែលទាក់ទងនឹងពាណិជ្ជកម្ម។ ទីមួយ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាននឹងកាត់បន្ថយចំណូលពន្ធលើការនាំចូល ឯការប្រកួតប្រជែងមានការកើនឡើងក្នុងចំណោមរដ្ឋជាសមាជិក ដែលនឹងអាចរួមចំណែកក្នុងការកាត់បន្ថយការនាំចេញ។ ទីពីរ សហភាពអឺរ៉ុបបានលើកឡើងពីលទ្ធភាពនៃការដកការអនុគ្រោះពន្ធ "ទំនិញគ្រប់មុខលើកលែងសព្វាវុធ" ពីកម្ពុជា ដែលនេះនឹងអាចកាត់បន្ថយការនាំចេញ ឧស្សាហកម្មកាត់ដេរ។ ចុងក្រោយ ភាពជោគជ័យរបស់កម្ពុជាក្នុងការប្រែក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប អាចមានន័យថាប្រទេសផ្សេងៗនឹងដកហូតការអនុគ្រោះពន្ធនាពេលខាងមុង។ យ៉ាងណាមិញ ស្ថានភាពខាងមុខក៏អាចជាកាលានុវត្តភាពផ្នែកពាណិជ្ជកម្មជាច្រើនផងដែរ ដោយមានសញ្ញាបង្ហាញថាក្រុមហ៊ុនលំដាប់ពិភពលោកដែលមានមូលដ្ឋាននៅប្រទេសចិនកំពុងផ្លាស់ប្តូរផលិតកម្មរបស់ខ្លួនមកប្រទេសកម្ពុជា វៀតណាម និងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងៗទៀត ខណៈភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិនត្រូវបានបន្ត។
- **កង្វះពិពិធភាពនៃកត្តាជំរុញកំណើន៖** លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសដែលបានជួយដល់សេដ្ឋកិច្ចកម្ពុជាមានប្រភពចម្បងតែមួយ (ពីប្រទេសចិន) ហើយត្រូវបានប្រមូលផ្តុំតែក្នុង វិស័យមួយចំនួនប៉ុណ្ណោះ រួមមានវិស័យសំណង់ និងវិស័យអចលនទ្រព្យ។

- **ភាពមិនប្រាកដប្រជានៃថវិការបស់ក្រសួងធនធានរ៉ែ និងថាមពល៖** ការផ្គត់ផ្គង់អគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជាគឺជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាល។ របាយការណ៍អនុវត្តន៍ចុងក្រោយបង្ហាញថាក្រសួងធនធានរ៉ែ និងថាមពល មិនបានសម្រេចតាមផែនការចំណាយក្នុងឆ្នាំ២០១៨ ។ ចំណាយក្រសួងនេះ មានកំណើនខ្ពស់ជាងគេក្នុងចំណាយថវិកាឆ្នាំ២០២០។ នេះហាក់ដូចជាការឆ្លើយតបនូវភាពជាក់ស្តែងដើម្បីដោះស្រាយវិស័យអាទិភាព។ ទោះយ៉ាងណា សមាជិកសភាអាចទទួលបានអត្ថប្រយោជន៍ពីការស្វែងយល់បន្ថែមអំពីគម្រោង និងហេតុផលនៃកំណើនចំណាយសម្រាប់ក្រសួងធនធានរ៉ែ និងថាមពល ដើម្បីពិនិត្យថា តើដំណើរការរៀបចំថវិកាប្រចាំឆ្នាំអាចត្រូវបានកែលម្អដូចម្តេចសម្រាប់វិស័យសំខាន់នេះ។
- **កំណើនឥណទានខ្ពស់ដល់វិស័យសំណង់ និងអចលនទ្រព្យ៖** ប្រសិនបើមានការធ្លាក់ចុះនៃការរំពឹងទុកលើវិស័យអចលនទ្រព្យ ឧទាហរណ៍ប្រសិនបើតម្រូវការធ្លាក់ចុះជាមួយនឹងវិបត្តិសេដ្ឋកិច្ចសកល ភាពជាម្ចាស់កម្មសិទ្ធិលើអចនទ្រព្យរបស់ពលរដ្ឋកម្ពុជាជាច្រើនអាចត្រូវបានគំរាមកំហែង។

# ក្របខណ្ឌផែនការសេដ្ឋកិច្ច

## ការសន្មតផែនការសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល

តារាងទី១: សូនាករសេដ្ឋកិច្ចសំខាន់ៗកម្ពុជា

| សូចនាករ | 2017 អនុវត្តន៍ | 2018 អនុវត្តន៍ | 2019 ប៉ាន់ប្រមាណ | 2020 គ្រោង | មធ្យម 2017-2020 |
|---|---|---|---|---|---|
| ផ.ស.ស ថ្លៃបច្ចុប្បន្ន(ប៊ីលានរៀល) | 88,647 | 98,786 | 108,590 | 119,034 | |
| កំណើនពិតផ.ស.ស (%) | 7.00 | 7.50 | 7.10 | 6.50 | 7.03 |
| ផ.ស.ស សម្រាប់មនុស្សម្នាក់(ដុល្លារអាមេរិក) | 1,427 | 1,548 | 1,679 | 1,816 | 1,618 |
| កំណើនផ.ស.សសម្រាប់មនុស្សម្នាក់ (%) | | 8.48 | 8.46 | 8.16 | 8.37 |
| អតិផរណា(%) | 2.90 | 2.50 | 2.80 | 2.90 | 2.78 |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លា) | 4,045 | 4,045 | 4,054 | 4,054 | 4,049.50 |
| សមតុល្យគណនីចរន្ត(% ផ.ស.ស) | (6.70) | (11.50) | (9.60) | (9.30) | (9.28) |
| ទុនបម្រុងអន្តរជាតិ(លានដុល្លារ) | 8,758 | 10,144 | 11,505 | 13,007 | 10,854 |
| កំណើនទុនបម្រុងអន្តរជាតិ(%) | | 15.83 | 13.42 | 13.06 | 14.10 |
| ទុនបម្រុងអន្តរជាតិ(គិតជាខែនៃការនាំចូល) | 6.40 | 5.60 | 5.80 | 6.10 | 6 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា[2, 4]*

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានៅតែមានភាពរឹងមាំ ទោះបីជារាជរដ្ឋាភិបាលរំពឹងថានឹងធ្លាក់ចុះបន្តិចក្នុងឆ្នាំ ២០២០ ក៏ដោយ។ តារាងទី ១ បង្ហាញពីការប៉ាន់ស្មានរបស់រាជរដ្ឋាភិបាល សម្រាប់សូចនាករសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជាក្នុងឆ្នាំ ២០២០ ប្រៀបធៀបនឹងនិន្នាការចាប់ពីឆ្នាំ ២០១៧ ។

ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ថ្លៃបច្ចុប្បន្ន បានកើនឡើងគួរឱ្យកត់សម្គាល់ពី ៨៨ ៦៤៧ ប៊ីលានរៀល ក្នុងឆ្នាំ ២០១៧ ដល់ ១០៨ ៥៩០ ប៊ីលានរៀលនៅឆ្នាំ ២០១៩ ហើយត្រូវបានព្យាករថានឹងកើនឡើង ដល់ ១១៩ ០៣៤ ប៊ីលានរៀលនៅឆ្នាំ ២០២០ ក្នុងអត្រាកំណើន ៦.៥%។ នេះគឺជាការធ្លាក់ចុះបន្តិច ធៀបនឹងអត្រាជាមធ្យម ៧.០% ពីឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៩ ដែលស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុត នៅក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងនេះ ផ. ស.ស សម្រាប់មនុស្សម្នាក់បានកើនឡើងពី ១ ៤២៧ ដុល្លារ ក្នុងឆ្នាំ ២០១៧ ដល់ ១ ៦៧៩ ដុល្លារក្នុងឆ្នាំ ២០១៩ ក្នុងអត្រាកំណើន ៨,៤% ជាមធ្យម ហើយត្រូវ បានព្យាករថានឹងកើនឡើងដល់ ១ ៨១៦ ដុល្លារនៅឆ្នាំ ២០២០ ក្នុងអត្រា៨,២% ។

អតិផរណាត្រូវបានគេព្យាករថានឹងបន្តនៅទាបជាង ៣.០% ក្នុងឆ្នាំ២០២០ ស្របនឹងអត្រាជាមធ្យម ២.៨% ពីឆ្នាំ ២០១៧។ អត្រាប្តូរប្រាក់ នឹងនៅត្រឹម ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ជាមធ្យមក្នុង រយៈពេលដូចគ្នា។ ឱនភាពគណនីចរន្តឈានដល់ ១១,៥% នៃផ.ស.សក្នុងឆ្នាំ ២០១៨ ប៉ុន្តែបានរួម តូច ហើយគ្រោងនឹងមាន ៩,៣% នៅឆ្នាំ ២០២០ ។

ទុនបម្រុងអន្តរជាតិ ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរពី ៨ ៧៥៨ លានដុល្លារក្នុងឆ្នាំ ២០១៧ ដល់ ១១ ៥០៥ លានដុល្លារក្នុងឆ្នាំ ២០១៩ ហើយត្រូវបានព្យាករថានឹងកើនឡើងដល់ ១៥ ០០៧ លាន ដុល្លារក្នុងឆ្នាំ ២០២០ ក្នុងអត្រាកំណើន ១៤.១% ស្មើនឹង ៦,១ ខែនៃការនាំចូល។

## ការវាយតម្លៃភាពសមហេតុផល

ដើម្បីវាយតម្លៃលើសនិទានភាពនៃការប៉ាន់ស្មានផែនការសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ការប៉ាន់ស្មាន ទាំងនោះត្រូវបានធៀបទៅនឹងការព្យាករពីប្រភពខាងក្រៅផ្សេងទៀត រួមមាន ធនាគារពិភពលោក (WB) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារអភិវឌ្ឍនអាស៊ី (ADB) (តារាងទី ២)។

ទោះបីជាមានភាពសុទិដ្ឋិនិយមខ្លះលើកម្រិតនៃ ផ.ស.ស ថ្លៃបច្ចុប្បន្ន (ដែលជាវិធានការណ៍ធំបំផុតនៃ មូលដ្ឋានគិតពន្ធ) ធៀបទៅនឹងអ្នកព្យាករណ៍ខាងក្រៅ ការប៉ាន់ស្មានផែនការរបស់រាជរដ្ឋាភិបាល គឺ មានសនិទានភាពខ្ពស់ ជាពិសេស៖

- រាជរដ្ឋាភិបាលរំពឹងថាផលិតផលក្នុងស្រុកសរុបនៅឆ្នាំ ២០២០ នឹងមានចំនួន ២៩ ៣៦២ លាន ដុល្លារអាមេរិកក្នុងអត្រាកំណើន៦.៥%។ មធ្យមភាគនៃការព្យាករខាងក្រៅគឺ ២៨ ៦០០ លាន ដុល្លារក្នុងអត្រាកំណើន ៦.៨%។ លទ្ធផលដែលហាក់ដូចជាផ្ទុយគ្នានេះ ផ្តើមចេញពីភាពខុសគ្នា នៃការប៉ាន់ស្មានផ.ស.ស ឆ្នាំ២០១៩។ រាជរដ្ឋាភិបាលប៉ាន់ស្មានចំណុចចាប់ផ្តើមខ្ពស់ជាងបន្តិច គឺក្នុងទំហំ ២៧ ២២២ លានដុល្លា ក្នុងឆ្នាំ២០១៩ ខណៈមធ្យមភាគនៃប្រភពខាងក្រៅមានត្រឹម តែ ២៦ ៤៨២ លានដុល្លា។

តារាងទី២៖ ការប្រៀបធៀបការផែនកាប៉ាន់ស្មានផែនការសេដ្ឋកិច្ចនៅឆ្នាំ ២០២០

| សូចនាករ | រាជរដ្ឋាភិបាល | ធនាគារ ពិភពលោក (WB) | មូលនិធិរូបបិយ-វត្ថុអន្តរជាតិ (IMF) | ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) | មធ្យម (WB, IMF & ADB) |
|---|---|---|---|---|---|
| ផ.ស.ស ថ្លៃបច្ចុប្បន្ន (លានដុល្លា) | 29,362 | 29,619 | 28,069 | 28,112 | 28,600 |
| កំណើនពិតនៃផ.ស.ស (%) | 6.5 | 6.9 | 6.7 | 6.8 | 6.8 |
| ផ.ស.ស សម្រាប់មនុស្សម្នាក់ៗ (ដុល្លារអាមេរិក) | 1,816 | 1,790 | 1,731 | 1,700 | 1,740 |
| អតិផរណា (%) | 2.9 | 3.0 | 2.9 | 2.5 | 2.8 |
| សមតុល្យគណនីចរន្ត (% GDP) | -9.3 | -9.1 | -9.4 | -13.5 | -10.7 |
| កំណើននៃការនាំចេញ (%) | 6.42 | 8.6 | 9.6 | | 9.1 |
| កំណើននៃការនាំចូល (%) | 7.19 | 7.1 | 8.3 | | 7.7 |
| ទុនបម្រុងអន្តរជាតិ(លានដុល្លា) | 13,007 | 11,184 | 10,970 | 12,300 | 11,485 |
| ទុនបម្រុងអន្តរជាតិ (ជាខែនៃការនាំចូល) | 6.1 | 6.2 | 4.9 | 6.0 | 5.7 |

*ប្រភព៖ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ធនាគារពិភពលោក មូលនិធិរូបបិយប័ណ្ណពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី[5, 6, 7]*

- ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ១ ៨១៦ ដុល្លារអាមេរិកនៅឆ្នាំ២០២០ ដែលខ្ពស់ជាងមធ្យមភាគនៃប្រភពខាងក្រៅដែលប៉ានស្មានចំនួន ១ ៧៤០ ដុល្លារអាមេរិក ដែលនេះជាលទ្ធផលកើតឡើងពីចំណុចចាប់ផ្តើមខុសគ្នាក្នុងឆ្នាំ២០១៩ ផងដែរ និងអាចដោយសារទិន្នន័យចំនួនប្រជាជនខុសគ្នា បន្ទាប់ពីការចេញផ្សាយទិន្នន័យជំរឿនថ្មីៗនេះ។
- អតិផរណា ត្រូវបានប៉ាន់ស្មានថាមានកម្រិតប្រហាក់ប្រហែលនឹងអត្រាជាមធ្យមនៃប្រភពខាងក្រៅ។
- សមតុល្យគណនីចរន្ត គឺប្រហាក់ប្រហែលនឹងធនាគារពិភពលោក និងIMF ប៉ុន្តែធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានអត្រាកំណើនខ្ពស់ ១៣.៥% ។
- ការប៉ាន់ស្មានរបស់រាជរដ្ឋាភិបាលអំពីកំណើននៃការនាំចេញ គឺមានលក្ខណៈជិតដល់ច្រើនជាងមធ្យមភាគនៃប្រភពខាងក្រៅ(៦,៤% ទល់នឹង ៩,១%) ខណៈដែលការនាំចូល ត្រូវបានប៉ាន់ស្មានថាទាបជាងជាមធ្យមភាគនៃប្រភពខាងក្រៅ (៧,២% ទល់នឹង ៧,៧%) ។
- ទុនបម្រុងអន្តរជាតិ ដែលរាជរដ្ឋាភិបាលព្យាករ ខ្ពស់ជាងមធ្យមភាគនៃប្រភពខាងក្រៅពោលគឺ ១៣ ០០៧លានដុល្លារធៀបនឹង ១១ ៤៨៥លានដុល្លារ ស្មើនឹងការនាំចូល ៦.១ខែធៀបនឹង ៥.៧ ខែ។

## ការវាយតម្លៃហានិភ័យសេដ្ឋកិច្ច

រាជរដ្ឋាភិបាល និងអ្នកសង្កេតពីប្រភពខាងក្រៅ បានទទួលស្គាល់នូវហានិភ័យមួយចំនួនចំពោះសេដ្ឋកិច្ចកម្ពុជា ទាំងពីកត្តាខាងក្រៅ និងក្នុងស្រុក[4]៖

### *កត្តាខាងក្រៅ*

**ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក៖** សេដ្ឋកិច្ចពិភពលោកត្រូវបានគេរំពឹងថានឹងមានការធ្លាក់ចុះ ជាពិសេសក្នុងចំណោមសេដ្ឋកិច្ចធំទាំង២ (កំណើនសេដ្ឋកិច្ចអាមេរិកត្រូវបានគេរំពឹងថានឹងធ្លាក់ចុះពី ២,៣% ក្នុងឆ្នាំ ២០១៩ ដល់ ១,៩% ក្នុងឆ្នាំ២០២០ ខណៈដែលសេដ្ឋកិច្ចចិននឹងធ្លាក់ចុះពី ៦,៣% ទៅ ៦,១%

ភាគច្រើនជាលទ្ធផលនៃសង្គ្រាមពាណិជ្ជកម្មរបស់ពួកគេ)។ កត្តាផ្សេងទៀត ដែលអាចជះឥទ្ធិពលដល់ទស្សនវិស័យរបស់ប្រទេសចិន រួមមានការកើនឡើងនៃឥណទានចិនដែលមិនមាននិរន្តរភាព និងបញ្ហានយោបាយ និងសង្គមផ្សេងទៀតរួមទាំងការផ្ទុះការតវ៉ានៅហុងកុង ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។

**កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងភាពមិនប្រាកដប្រជានៃពាណិជ្ជកម្ម៖** ប្រទេសកម្ពុជាប្រឈមនឹងការគំរាមកំហែងមួយចំនួនចំពោះការនាំចេញ និងបញ្ហាចំណូលដែលទាក់ទងនឹងពាណិជ្ជកម្ម។ **ទីមួយ** កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន នឹងកាត់បន្ថយចំណូលពន្ធលើការនាំចូល ហើយការប្រកួតប្រជែងនឹងមានការកើនឡើងក្នុងចំណោមរដ្ឋជាសមាជិកដែលអាចធ្វើឱ្យការនាំចេញធ្លាក់ចុះ។ **ទីពីរ** សហភាពអឺរ៉ុបបានលើកឡើងពីលទ្ធភាពនៃការដកហូតអនុគ្រោះពន្ធ "ទំនិញគ្រប់មុខលើកលែងសព្វាវុធ" ពីកម្ពុជា ដែលអាចកាត់បន្ថយការនាំចេញក្នុងឧស្សាហកម្មកាត់ដេរ។ ចុងក្រោយ ភាពជោគជ័យរបស់កម្ពុជាក្នុងការប្រែក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប មានន័យថាប្រទេសផ្សេងទៀតអាចនឹងដកហូតការអនុគ្រោះពន្ធជាបណ្តើរៗ។ ទោះយ៉ាងណាក៏ដោយ កម្ពុជានៅមានកាលានុវត្តភាពពាណិជ្ជកម្មជាច្រើន ដោយមានសញ្ញាបង្ហាញថាក្រុមហ៊ុនលំដាប់ពិភពលោក ដែលមានមូលដ្ឋាននៅប្រទេសចិនកំពុងផ្លាស់ប្តូរផលិតកម្មរបស់ខ្លួនមកប្រទេសកម្ពុជា វៀតណាម និងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀត ខណៈភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក និងចិនត្រូវស្ថិតនៅបន្ត[8]។

### *កត្តាខាងក្នុង*

**បញ្ហាប្រឈមនៃរចនាសម្ព័ន្ធ៖** រាជរដ្ឋាភិបាលបានកំណត់បញ្ហាប្រឈមមានលក្ខណៈជារចនាសម្ព័ន្ធមួយចំនួនក្នុងប្រទេសដែលត្រូវដោះស្រាយដើម្បីជំរុញកំណើន។ បញ្ហាប្រឈមទាំងនោះ រួមមាន៖ ថ្លៃអគ្គិសនីខ្ពស់សម្រាប់អ្នកផលិត និងអ្នកលក់រាយធៀបនឹងប្រទេសជិតខាង ភាពទន់ខ្សោយខាងប្រព័ន្ធដឹកជញ្ជូន ផលិតភាពកម្លាំងពលកម្មទាប កង្វះកម្លាំងជំនាញ និងនីតិវិធីពាណិជ្ជកម្មស្មុគស្មាញ និងថ្លៃដើមខ្ពស់[4]។

**ភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ៖** IMF មានការព្យាករថា កម្ពុជាអាចមានភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ ដែលជាការគំរាមកំហែងដល់ចក្ខុវិស័យ ជាពិសេសឥណទានក្នុងស្រុក ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ដែលជាប់ទាក់ទងនឹងបញ្ហាអចលនទ្រព្យ[7]។

**ថ្លៃដើមនៃការខ្ចីកាន់តែខ្ពស់៖** កម្ចីសម្បទានអាចនឹងមានកម្រិត នៅពេលដែលសេដ្ឋកិច្ចកម្ពុជារីកចម្រើនបន្ថែមទៀតក្នុងនាមជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ កត្តានេះអាចធ្វើឲ្យចំណាយលើកម្ចីហិរញ្ញប្បទានមានថ្លៃដើមកាន់តែខ្ពស់។

**កង្វះកត្តាជំរុញកំណើន និងការពឹងផ្អែកលើវិស័យសំណង់ និងអចលនទ្រព្យ៖** ធនាគារពិភពលោកបានកំណត់ថា ការពឹងផ្អែករបស់ប្រទេសកម្ពុជាលើវិស័យសំណង់ និងអចលនទ្រព្យ ជាប្រភពនៃហានិភ័យដែលសេដ្ឋកិច្ចងាយនឹងធ្លាក់ចូលវដ្តឡើងចុះរហ័ស និងគំរាមកំហែងដល់ការសាយភាយដល់ទីផ្សារឥណទានក្នុងស្រុក បង្កើនភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុ[6]។

# ទស្សនវិស័យសារពើពន្ធ

## ចំណូលថវិកា

តារាង ទី៣៖ តារាងសង្ខេបចំណូលថវិកា (ប៊ីលានរៀល)

| ចំណូល (ប៊ីលានរៀល) | អនុវត្តន៍ | | | ថវិកា | | កំណើន | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | (%) | 2016-2019 |
| **ចំណូលក្នុងប្រទេស** | 14,398 | 17,109 | 20,341 | 19,786 | 24,093 | 21.8% | 14.6% |
| ចំណូលសារពើពន្ធក្នុងស្រុក | 10,188 | 12,543 | 14,925 | 14,468 | 18,322 | 26.6% | 16.2% |
| ពន្ធលើប្រាក់ចំណូល | 2,953 | 3,798 | 4,059 | 4,330 | 5,080 | 17.3% | 15.8% |
| ពន្ធប្រយោល | 4,189 | 4,936 | 5,729 | 5,902 | 7,373 | 24.9% | 15.1% |
| អាករពិសេស | 2,955 | 3,676 | 4,969 | 4,137 | 5,734 | 38.6% | 19.0% |
| ចំណូលសារពើពន្ធផ្សេងទៀត | 91 | 133 | 168 | 100 | 135 | 35.7% | 16.2% |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2,010 | 1,977 | 2,371 | 2,411 | 2,769 | 14.9% | 7.0% |
| ចំណូលមិនមែនសារពើពន្ធ | 2,080 | 2,446 | 2,851 | 2,714 | 2,808 | 3.5% | 16.2% |
| ចំណូលមូលធន[2] | 120 | 142 | 195 | 193 | 193 | 0.1% | 10.7% |
| **% ផ.ស.ស** | | | | | | | |
| **ចំណូលក្នុងប្រទេស** | 17.7% | 19.1% | 20.6% | 18.2% | 20.2% | | |
| ចំណូលសារពើពន្ធក្នុងស្រុក | 12.5% | 14.0% | 15.1% | 13.3% | 15.4% | | |
| ពន្ធលើប្រាក់ចំណូល | 3.6% | 4.2% | 4.1% | 4.0% | 4.3% | | |
| ពន្ធប្រយោល | 5.2% | 5.5% | 5.8% | 5.4% | 6.2% | | |
| អាករពិសេស | 3.6% | 4.1% | 5.0% | 3.8% | 4.8% | | |
| ចំណូលសារពើពន្ធផ្សេងទៀត | 0.1% | 0.1% | 0.2% | 0.1% | 0.1% | | |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.5% | 2.2% | 2.4% | 2.2% | 2.3% | | |
| ចំណូលមិនមែនសារពើពន្ធ | 2.6% | 2.7% | 2.9% | 2.5% | 2.4% | | |
| ចំណូលមូលធន | 0.1% | 0.2% | 0.2% | 0.2% | 0.2% | | |

*ប្រភព: ច្បាប់ទូទាត់ (ឆ្នាំ២០១៥-២០១៨), ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង (ឆ្នាំ២០១៩-២០២០)*

## ក្របខណ្ឌផែនការ

ចំណូលថវិកាក្នុងប្រទេសត្រូវបានគេរំពឹងថានឹងកើនដល់ ២៤ ០៩៣ ប៊ីលានរៀលនៅឆ្នាំ ២០២០ មានកំណើន ២១,៨% ធៀបនឹងឆ្នាំ ២០១៩ ឬស្មើនឹង ២០,២% នៃផ. ស.ស (តារាងទី ៣)។ កំណើននេះត្រូវបានជំរុញដោយកំណើនលើចំណូលពន្ធប្រយោល (ជាពិសេស អាករលើតម្លៃបន្ថែម) និងអាករពិសេស។

ពន្ធប្រយោលត្រូវបានរំពឹងថានឹងកើនឡើងប្រមាណ ២៤,៩% ពីឆ្នាំ២០១៩ ដែលលើសពីកំណើនមធ្យមប្រមាណ១៥,១% ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ។ ពន្ធប្រយោល គឺជាប្រភពចំណូលចម្បង និងត្រូវបានគេរំពឹងថានឹងមានចំនួន ៣៥,០% នៃប្រាក់ចំណូលពន្ធសរុប ឬ ៦,២% នៃផ.ស.ស នៅឆ្នាំ២០២០។

[2] រួមបញ្ចូលចំណូលពីប្រភពផ្ទាល់ ប៉ុន្តែមិនរួមបញ្ចូលចំណូលពីប្រភពខាងក្រៅ

អាករពិសេសត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៣៨,៦% លើសពីកំណើនជាមធ្យមដែលមានតែ ១៩%។ ចំណូលអាករពិសេស មានចំនួន ២៧,២% នៃចំណូលពន្ធសរុប ឬ ៤,៨ % នៃផ.ស.ស។
ពន្ធលើប្រាក់ចំណូលត្រូវបានគេរំពឹងថានឹងកើនឡើង ១៧,៣% ក្នុងឆ្នាំ២០២០ ខ្ពស់ជាងកំណើនជាមធ្យម ១៥,៨% ពីឆ្នាំ ២០១៦ដល់ឆ្នាំ២០១៩ ។
ពន្ធលើពាណិជ្ជកម្មក្រៅប្រទេសត្រូវបានគេរំពឹងថានឹងកើនឡើង ១៤,៩% ធៀបទៅនឹងថវិកាឆ្នាំ ២០១៩ ដោយមានកំណើនជាមធ្យមប្រមាណ ៧,០% ពីឆ្នាំ ២០១៦ដល់ឆ្នាំ២០១៩។

# ចំណាយថវិកា

## ក្របខណ្ឌផែនការ៖ វិភាជន៍តាមមូលដ្ឋានសេដ្ឋកិច្ច

ចំណាយថវិកាសរុប ត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៣១ ០៩៦ ប៊ីលានរៀល កើនឡើង ២១ % ធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង ២៦% នៃផ.ស.ស នៅឆ្នាំ ២០២០ (តារាងទី៤)។ ចំណាយមូលធនត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ១៣ ០៥៩ ប៊ីលានរៀល និងមានកំណើនគួរឱ្យកត់សម្គាល់ ប្រមាណ ៤៦% ធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង ១១%នៃផ.ស.ស។ ការកើនឡើងនេះគឺដោយសារតែកំណើនយ៉ាងឆាប់រហ័សនៃចំណាយការវិនិយោគសាធារណៈដែលមិនទាន់បែងចែក ដែលត្រូវបានគេរំពឹងថា

តារាងទី៤៖ សង្ខេបនៃការចំណាយ

| **ចំណាយ** (ប៊ីលានរៀល) | អនុវត្តន៍ | | | ច្បាប់ហិរញ្ញវត្ថុ | | កំណើន | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | 2020 | 2015-2020 |
| **ការចំណាយសរុប** | **16,928** | **20,016** | **22,551** | **25,765** | **31,096** | **21%** | **16%** |
| ចំណាយចរន្តសរុប | 10,876 | 13,237 | 14,973 | 16,827 | 18,037 | 7% | 15% |
| **បន្ទុកបុគ្គលិក** | 5,506 | 6,838 | 8,001 | 7,863 | 8,540 | 9% | 14% |
| **ភាគរយ ចំណាយចរន្ត** | 51% | 52% | 53% | 47% | 47% | | |
| រដ្ឋបាលស៊ីវិល | 3,432 | 4,265 | 4,946 | | | | |
| ការពារជាតិ និងសន្តិសុខ | 2,074 | 2,573 | 3,055 | | | | |
| **មិនមែនបន្ទុកបុគ្គលិក** | 5,370 | 6,399 | 6,971 | 8,965 | 9,497 | 6% | 17% |
| **ភាគរយ ចំណាយចរន្ត** | 49% | 48% | 47% | 53% | 53% | | |
| ការទិញទំនិញ | 1,300 | 1,408 | 1,529 | | | | |
| សេវាកម្ម | 1,357 | 1,582 | 1,687 | | | | |
| បន្ទុកហិរញ្ញវត្ថុ | 335 | 342 | 387 | 525 | 542 | 3% | 21% |
| ការឧបត្ថមធន | 1,018 | 1,381 | 1,349 | | | | |
| អត្ថប្រយោជន៍សង្គម | 973 | 1,087 | 1,336 | | | | |
| ពន្ធ និងអាករ | 299 | 452 | 472 | | | | |
| ផ្សេងៗ( ការអនុវត្តគម្រោង ) | 89 | 147 | 210 | | | | |
| ចំណាយមូលធនសរុប | 6,051 | 6,779 | 7,579 | 8,938 | 13,059 | 46% | 19% |

| % ផ.ស.ស | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|
| **ចំណាយសរុប** | 21% | 22% | 23% | 24% | 26% |
| ចំណាយចរន្តសរុប | 13% | 15% | 15% | 15% | 15% |
| **បន្ទុកបុគ្គលិកសរុប** | 7% | 8% | 8% | 7% | 7% |
| រដ្ឋបាលស៊ីវិល | 4% | 5% | 5% | | |
| ការពារជាតិ និងសន្តិសុខ | 3% | 3% | 3% | | |
| **មិនមែនបន្ទុកបុគ្គលិកសរុប** | 7% | 7% | 7% | 8% | 8% |
| ការទិញទំនិញ | 2% | 2% | 2% | | |
| សេវាកម្ម | 2% | 2% | 2% | | |
| បន្ទុកហិរញ្ញវត្ថុ | 0.4% | 0.4% | 0.4% | 0.5% | 0.5% |
| ការឧបត្ថមធន | 1% | 2% | 1% | | |
| អត្ថប្រយោជន៍សង្គម | 1% | 1% | 1% | | |
| ពន្ធ និងអាករ | 0.4% | 0.5% | 0.5% | | |
| ផ្សេងៗ (អនុវត្តគម្រោង) | 0.1% | 0.2% | 0.2% | | |
| ចំណាយមូលធនសរុប | 7% | 8% | 8% | 8% | 11% |

*ប្រភព: ច្បាប់ទូទាត់ (២០១៥-២០១៨), ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង (២០១៩-២០២០)*

នឹងមានចំនួន ៣ ៨៨៦ ប៊ីលានរៀលក្នុងឆ្នាំ២០២០ ធៀបទៅនឹង ៦៣៦ លានរៀល នៅក្នុងឆ្នាំ២០១៩។ ចំណាយមូលធននៅឆ្នាំ ២០២០ ត្រូវបានបម្រុងទុកសម្រាប់គាំទ្រដល់កម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល (២០២០-២០២២) ដោយប្រើប្រាស់ហិរញ្ញប្បទានទាំងក្នុង និងក្រៅប្រទេស។

ការចំណាយថវិកាចរន្តសរុប ត្រូវបានគ្រោងចំនួន ១៨ ០៣៧ ប៊ីលានរៀល នៅឆ្នាំ២០២០ កើនឡើង ៧% ធៀបនឹងឆ្នាំ២០១៩ ដែលស្មើនឹង ១៥% នៃផ.ស.ស។ ចំណាយបន្ទុកបុគ្គលិកសរុបត្រូវបានគេរំពឹងថានឹងកើនឡើងដល់ ៩% បើធៀបទៅនឹងឆ្នាំ២០១៩ ដែលស្មើនឹង ៤៧% នៃចំណាយថវិកាចរន្តសរុប ឬស្មើ ៧% នៃផ.ស.ស។ ស្រដៀងគ្នានេះដែរ ការចំណាយមិនមែនបន្ទុកបុគ្គលិកសរុបត្រូវបានគ្រោងបង្កើនប្រមាណ ៦% ដែលស្មើនឹង ៨% នៃផ.ស.សនៅឆ្នាំ ២០២០ ។

## ក្របខណ្ឌផែនការះ វិភាជន៍តាមមុខងារ និងក្រសួង

ថវិកាជាតិកម្ពុជាចែកចេញជាប្រាំវិស័យ។ ក្នុងឆ្នាំ២០២០ ចំណាយចរន្តដែលបានវិភាជសម្រាប់វិស័យសង្គមកិច្ចមានចំនួន ៦ ៧៤៨ ប៊ីលានរៀល កើនឡើងប្រមាណ ៨,៩%ធៀបឆ្នាំ២០១៩។ ចំណាយសម្រាប់វិស័យសង្គមកិច្ចនៅតែបន្តធំជាងគេនៃចំណាយចរន្តសរុប ក្នុងអត្រា ៣៧,៤% ដែលស្របនឹងការចាត់អាទិភាពរបស់រាជរដ្ឋាភិបាល ដែលវិស័យនេះផ្តោតលើការអភិវឌ្ឍធនធានមនុស្ស រួមមាន៖ ការអប់រំ សុខភាព កម្លាំងពលកម្ម និងកិច្ចការសង្គមផ្សេងទៀត (តារាងទី៥)។ ឯថវិកាជាតិដែលបានវិភាជ សម្រាប់វិស័យការពារជាតិ និងសន្តិសុខសាធារណៈកើនឡើង ៩,៣% ស្មើនឹង ២៥,៨% នៃចំណាយចរន្តសរុប។

ចំណែកវិស័យសេដ្ឋកិច្ចនឹងកើនឡើង ៣,៣% តែមិនបានរាប់បញ្ចូលការវិនិយោគក្នុងចំណាយមូលធន ដែលជាសមាសភាគសំខាន់មួយរបស់រាជរដ្ឋាភិបាលនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចទេ។

នៅក្នុងឆ្នាំ២០២០ ចំណាយមិនទាន់បែងចែកត្រូវបានរំពឹងទុកថានឹងមានកំណើន ៤,១% ស្មើនឹង ១៥,១% នៃចំណាយចរន្តសរុប ដែលមានទឹកប្រាក់ស្មើនឹង ២ ៧២១ ប៊ីលានរៀល ដែលចំនួនតួលេខ នេះប្រហាក់ប្រហែលទៅនឹងតួលេខក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១៩។

តារាងទី៥៖ សង្ខេបចំណាយតាមវិស័យ (២០១៦-២០២០)

| ចំណាយចរន្តតាមវិស័យ | ភាគរយនៃចំណាយចរន្តសរុប (%) | | | | | កំណើន | កំណើនជាមធ្យម (%) |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | 2019-2020 | 2016-2019 |
| វិស័យរដ្ឋបាលទូទៅ | 17.3% | 19.2% | 16.5% | 13.3% | 13.0% | 4.7% | 10.8% |
| វិស័យការពារជាតិ និងសន្តិសុខ | 26.3% | 25.7% | 26.6% | 25.3% | 25.8% | 9.3% | 16.2% |
| វិស័យសង្គមកិច្ច | 36.8% | 36.6% | 38.4% | 36.8% | 37.4% | 8.9% | 15.0% |
| វិស័យសេដ្ឋកិច្ច | 10.5% | 10.0% | 9.3% | 9.0% | 8.6% | 3.3% | 9.2% |
| ចំណាយមិនទាន់បែងចែក | 9.0% | 8.6% | 9.1% | 15.5% | 15.1% | 4.1% | 26.5% |

*ប្រភព៖ ច្បាប់ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*

តារាងទី៦ បង្ហាញពីចំណាយតាមក្រសួង ស្ថាប័ន ចំនួន១០ ដែលមានភាគរយខ្ពស់ជាងគេនៅក្នុងឆ្នាំ ២០២០ ធៀបទៅនឹងចំណាយចរន្តថ្នាក់ជាតិសរុប (តារាងពិស្តារមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ)។ ចំណាត់ថ្នាក់នេះឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការជំរុញវិស័យអាទិភាព។ យោង តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងអាទិភាពទីមួយ

តារាងទី៦៖ សង្ខេបចំណាយចរន្តតាមក្រសួង ស្ថាប័ន (២០១៦-២០២០)

| ចំណាយចរន្តតាមក្រសួង ស្ថាប័ន | ភាគរយនៃចំណាយចរន្តសុរប (%) | | | | | កំណើន | កំណើនជាមធ្យម |
|---|---|---|---|---|---|---|---|
| | 2016 | 2017 | 2018 | 2019 | 2020 | 2020 | 2016-2019 |
| ក្រសួងអប់រំ យុវជន និងកីឡា | 17.0% | 17.1% | 17.9% | 17.5% | 17.8% | 8.7% | 16.7% |
| ក្រសួងការពារជាតិ | 14.9% | 14.4% | 14.9% | 14.4% | 14.1% | 5.0% | 14.0% |
| ក្រសួងមហាផ្ទៃ | 10.6% | 10.5% | 10.9% | 10.1% | 10.9% | 15.4% | 8.9% |
| ក្រសួងសុខាភិបាល | 9.7% | 8.9% | 9.2% | 9.2% | 9.1% | 5.9% | 11.3% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 6.3% | 6.0% | 6.0% | 5.9% | 6.3% | 14.5% | 13.7% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 5.3% | 7.0% | 5.4% | 4.7% | 4.9% | 11.3% | 20.4% |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 5.2% | 5.0% | 3.9% | 2.5% | 2.4% | 2.8% | 3.8% |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | 3.5% | 2.9% | 2.6% | 2.4% | 2.3% | -0.6% | 4.1% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1.6% | 1.6% | 1.6% | 1.6% | 1.6% | 6.9% | 13.8% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1.5% | 1.7% | 2.0% | 1.4% | 1.5% | 14.3% | 21.0% |

*ប្រភព៖ ច្បាប់ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*

ដោយក្រសួងនេះទទួលបានការវិភាជថវិកាជាតិប្រមាណ ១៧,៨% នៃចំណាយចរន្តសរុប កើនឡើង ៨,៧%ប៉ុន្តែយឺតជាងកំណើនជាមធ្យម។ ក្រសួងការពារជាតិស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ ដោយមានភាគរយនៃចំណាយចរន្តសរុប ១៤,១% និងក្រសួងមហាផ្ទៃចំណាត់ថ្នាក់ទី៣ មាន ១០,៩% ។ ក្រសួងសុខាភិបាលក៏មាននៅក្នុងចំណាត់ថ្នាក់ក្រសួងទាំងដប់ដែរ គឺចំណាយ ៩,១% នៃចំណាយចរន្តសរុប។ ចំណាយក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវបានរំពឹងថានឹងធ្លាក់ចុះបន្តិចនៅក្នុងឆ្នាំ២០២០។

## រដ្ឋបាលថ្នាក់ក្រោមជាតិ

តារាងទី៧ បង្ហាញថា ចំណូល ចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានគ្រោងនៅក្នុងឆ្នាំ២០២០ មានចំនួនប្រមាណ ៣ ៣២៩ ប៊ីលានរៀល ស្មើនឹង ២,៨% នៃផ.ស.ស កើនឡើង ៥១% ធៀបនឹងឆ្នាំ ២០១៩ នឹងកើនឡើង ៧ ដង ធៀបនឹងឆ្នាំ២០១៦។
ថវិការដ្ឋបាលរាជធានី ខេត្ត មានចំណែកធំជាងគេ ស្មើនឹង ១,៩% នៃផ.ស.ស ឬស្មើនឹង ៦៨,៤% នៃចំណាយថវិកាសរុបនៅថ្នាក់ក្រោមជាតិ រីឯរដ្ឋបាលស្រុក ខណ្ឌ មានចំនួន ០,២% និងរដ្ឋបាលឃុំ សង្កាត់ ចំនួន ០,៧% នៃផ.ស.ស។

តារាងទី៧ ក៏បានបង្ហាញផងដែរថា ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិពឹងផ្អែកយ៉ាងខ្លាំងទៅលើការឧបត្ថម្ភធនពីថ្នាក់ជាតិដែលស្មើនឹង ៣៦,២% ជាមធ្យម ពីឆ្នាំ២០១៥-២០២០ ជាពិសេសសម្រាប់ឧបត្ថម្ភដល់រដ្ឋបាលស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ ការធ្វើឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនឡើងជារៀងរាល់ឆ្នាំ ហើយបានបន្តកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០២០ រហូតដល់ ១ ០៨៥ ប៊ីលានរៀល កើនឡើង ៣៤,៧% ធៀបនឹងឆ្នាំ២០១៩។ ការកើនឡើងនេះគឺជាលទ្ធផលនៃការដំឡើងប្រាក់បំណាច់ជូនដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាមន្ត្រីភូមិ ដែលនឹងចាប់ផ្តើមអនុវត្តពីខែមេសា ឆ្នាំ២០២០។ មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏នឹងកើនឡើងទ្វេដង ដល់ ២៨៤ លានរៀល ឬសមមូលស្មើនឹង ៧០ ០០០ ដុល្លារអាមេរិក ជាមធ្យមសម្រាប់ឃុំ សង្កាត់នីមួយៗនៅឆ្នាំ២០២០ តាមរយៈកញ្ចប់ថវិកាអន្តរាគមន៍ដែលទើបបង្កើតថ្មី។

តារាង៧៖ ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ឆ្នាំ២០២០

| ចំណូល ចំណាយ<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ទឹកប្រាក់<br>(ប៊ីលានរៀល) | % នៃផ.ស.ស<br>(ការព្យាករ) | % នៃចំណាយ<br>ថវិកាជាតិសរុប | % នៃថវិការដ្ឋបាល<br>ថ្នាក់ក្រោមជាតិសរុប |
|---|---|---|---|---|
| រដ្ឋបាលរាជធានី ខេត្ត | 2,279 | 1.9% | 6.6% | 68.4% |
| រដ្ឋបាលក្រុង ស្រុក | 247 | 0.2% | 0.7% | 7.4% |
| រដ្ឋបាលឃុំ សង្កាត់ | 803 | 0.7% | 2.3% | 24.1% |
| សរុបចំណូល ចំណាយ | 3,329 | 2.8% | 9.7% | |
| សរុបឧបត្ថម្ភធនពីថ្នាក់ជាតិ | 1,085 | 0.9% | 3.2% | 32.6% |
| សរុបចំណាយចរន្ត | 2,244 | 1.9% | 6.5% | 67.4% |

*ប្រភព៖ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០[1]*

តារាង៨៖ ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ ពីឆ្នាំ២០១៥-២០២០ (ប៊ីលានរៀល)

| ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ | 2015 | 2016 | 2017 | 2018 | 2019 | 2020 | កំណើនឆ្នាំ 2020 | កំណើនមធ្យមឆ្នាំ2016-2020 |
|---|---|---|---|---|---|---|---|---|
| រាជធានី ខេត្ត | 896 | 946 | 1,177 | 1,891 | 1,477 | 2,279 | 54% | 25% |
| ស្រុក ខណ្ឌ | 98 | 118 | 147 | 176 | 199 | 247 | 24% | 20% |
| ឃុំ សង្កាត់ | 294 | 312 | 352 | 430 | 524 | 803 | 53% | 23% |
| សរុបចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ (1) | 1,288 | 1,376 | 1,676 | 2,497 | 2,200 | 3,329 | 51% | 23% |
| ឧបត្ថម្ភធនពីថ្នាក់ជាតិ (2) | 443 | 560 | 653 | 852 | 800 | 1,085 | 35.74% | 20.65% |
| % (2) នៃ (1) | 34% | 41% | 39% | 34% | 36% | 33% | | |
| **%(1) នៃថវិការដ្ឋសរុប** | 8% | 7.5% | 7.7% | 9.9% | 7.8% | 9.6% | | |

*ប្រភព៖ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥-២០១៨ និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*

ផ្អែកលើមូលដ្ឋាននៃចំណាយរដ្ឋបាលរាជធានី ខេត្តគិតក្នុងមនុស្សម្នាក់ៗ ទំហំចំណាយនៅរាជធានីភ្នំពេញនៅតែខ្ពស់ជាងគេក្នុងឆ្នាំ២០២០ គឺកើនដល់ ៧៨១ ៤៨០រៀល។ ការចំណាយសម្រាប់មនុស្សម្នាក់នៅខេត្តព្រះសីហនុ បានកើនឡើងគួរឱ្យកត់សម្គាល់ ដល់ ៤៣២ ២៤៤រៀលដែលកើនពី ១៧១ ២៤៤រៀល ក្នុងឆ្នាំ២០១៩។ ខេត្តមួយចំនួន រួមមាន ខេត្តប៉ៃលិន និងមណ្ឌលគិរីមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ការចំណាយមនុស្សម្នាក់ៗនៅខេត្តព្រៃវែងគឺទាបជាងគេបំផុត មានតែ ១៣ ១៣៩រៀលប៉ុណ្ណោះ។

រូបទី២៖ រាជធានីភ្នំពេញឈរលំដាប់ខ្ពស់សម្រាប់ចំណាយរដ្ឋបាលរាជធានី ខេត្ត ក្នុងមនុស្សម្នាក់ (គិតជារៀល)




*ប្រភព៖ សេចក្តីព្រាងច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩[1, 9]*

# តុល្យភាពថវិកា និងហិរញ្ញវត្ថុ

## តុល្យភាពថវិកា

ឱនភាពសរុបថវិកាជាតិឆ្នាំ២០២០ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៧ ០០៣ ប៊ីលានរៀល ស្មើនឹង ៥,៨% នៃ ផ.ស.ស ដែលឱនភាពនេះកើនពី ៥ ៩៧៩ ប៊ីលានរៀល នៅឆ្នាំ២០១៩ (តារាងទី៩)។

តុល្យភាពនៃចំណាយចរន្តនៅមានអតិរេក និងកំពុងតែមានការកើនឡើងដល់ទៅ ៥ ៨៦២ ប៊ីលានរៀល ស្មើនឹង ១១២% ធៀបទៅនឹងឆ្នាំ២០១៩។ ក្នុងន័យនេះ ការកើនឡើងនៃកម្ចីគឺភាគច្រើនពាក់ព័ន្ធទៅនឹងការវិនិយោគមូលធនរបស់រាជរដ្ឋាភិបាល ពោលគឺការអនុវត្តកម្មវិធីវិត្ថារកម្ម ដើម្បីបង្កើនការវិនិយោគ។

តារាងទី៩៖ តុល្យភាពថវិកា (២០១៦-២០២០)

| តុល្យភាពថវិកា | | អនុវត្តន៍ | | | ច្បាប់ | |
|---|---|---|---|---|---|---|
| | | 2016 | 2017 | 2018 | 2019 | 2020 |
| អតិរេក | ប៊ីលានរៀល | 3,401 | 3,730 | 5,174 | 2,766 | 5,862 |
| គណនេយ្យចរន្ត | % ផ.ស.ស | 4.41 | 4.43 | 5.61 | 2.84 | 5.31 |
| ឱនភាពសរុបថវិកា | ប៊ីលានរៀល | (2,530) | (2,907) | (2,210) | (5,979) | (7,003) |
| ជាតិ | % ផ.ស.ស | -3.11 | -3.24 | -2.30 | -5.51 | -5.88 |

*ប្រភព៖ ច្បាប់ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*

## គម្រោងកម្ចី និងបំណុល

ដើម្បីផ្តល់ហិរញ្ញប្បទានឱនភាពថវិកាជាតិ រាជរដ្ឋាភិបាលបានស្វែងរកជំនួយ និងកម្ចីពីទ្វេភាគី និងពហុភាគី។ តារាងទី១០ បង្ហាញថាកម្ចីត្រូវបានរំពឹងថានឹងកើនដល់ ៥ ១៨៣ ប៊ីលានរៀលនៅក្នុងឆ្នាំ២០២០។

តារាងទី១០៖ សង្ខេបកម្ចី (២០១៦-២០២០)

| កម្ចី (ប៊ីលានរៀល) | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|
| កម្ចីសរុប | 2,468 | 2,218 | 2,922 | 2,613 | 4,384 | 5,183 |
| % នៃ ផ.ស.ស | 3.0% | 2.73% | 3.26% | 2.65% | 4.04% | 4.35% |

*ប្រភព៖ ច្បាប់ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*

នៅត្រឹមចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលព្យាករថាកម្ពុជានឹងមានបំណុលសាធារណៈសរុបប្រមាណ ២១,៣% នៃផ.ស.ស ដែលក្នុងនោះ ០,០៤% គឺជាបំណុលសាធារណៈក្នុងស្រុក (តារាង១១) សូចនាករទាំងអស់មានស្ថិរភាព និងទាបជាងអនុបាតគោលដែលជាកម្រិតនៃការព្រួយបារម្ភ។

សរុបមក ថ្លៃសេវាបំណុលមានការផ្តល់សម្បទានខ្ពស់នៅក្នុងអត្រាការប្រាក់ជាមធ្យម ០,៥% នៅក្នុងរយៈពេលអនុគ្រោះ ៨ឆ្នាំ និងរយៈពេលសង ២៥,៥ឆ្នាំ។

តារាងទី១១៖ ទស្សនវិស័យពីបំណុល

| សូចនាករ (អនុបាត) | 2015 | 2016 | 2017 | 2018 | 2019e | អនុបាតគោល |
|---|---|---|---|---|---|---|
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈធៀបទៅនឹងផ.ស.ស | 23.2 | 22.5 | 22.8 | 21.5 | 21.3 | 55 |
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផ.ស.ស | 33.5 | 31.6 | 22.8 | 21.5 | 21.3 | 40 |
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹងការនាំចេញ | 147.6 | 138.2 | 30.8 | 28.4 | 27.5 | 180 |
| សន្និធិបំណុល ធៀបនឹង ផ.ស.ស | 31.2 | 29.1 | 30.0 | 28.6 | 29.6 | |
| សេវាបំណុលសារធាណៈធៀបនឹងការនាំចេញ | 1.3 | 1.4 | 1.3 | 1.4 | 1.5 | 15 |
| សេវាបំណុលសាធារណៈធៀបនឹងចំណូល | 5.7 | 6.1 | 4.7 | 4.9 | 5.1 | 18 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគណនារបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា [10]*

# ហានិភ័យចំពោះទស្សនវិស័យសារពើពន្ធ

**ភាពមិនច្បាស់លាស់នៃថវិការបស់ក្រសួងធនធានរ៉ែ និងថាមពល៖** ការផ្គត់ផ្គង់អគ្គិសនី គឺជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។ យោងតាមរបាយការណ៍ចុងក្រោយនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាជាតិឆ្នាំ២០១៨ បានបង្ហាញថាក្រសួងធនធានរ៉ែ និងថាមពល មានចំណាយជាក់ស្តែងទាបជាងគេបង្អស់ធៀបនឹងផែនការឆ្នាំ២០១៨។ ការចំណាយរបស់ក្រសួងនេះបានកើនឡើងក្នុងឆ្នាំ២០២០ ដែលហាក់ដូចជាឆ្លើយតបទៅនឹងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។ ទោះយ៉ាងណា សមាជិកសភាអាចទទួលបានអត្ថប្រយោជន៍ពីការសិក្សាបន្ថែមអំពីគម្រោង និងការចំណាយអាទិភាពរបស់ក្រសួងនេះ ដើម្បីពិនិត្យមើល និងកែលម្អទៅលើដំណើរការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួងដែលជាវិស័យអាទិភាពនេះអោយកាន់តែល្អប្រសើរ។

**កំណើនបៀវត្សសារធារណៈ៖** បៀវត្សសាធារណៈមានកំណើន ៨,៦% ធៀបទៅនឹងឆ្នាំ២០១៩ ស្មើនឹង ៧,២ ភាគរយ នៃ ផ.ស.ស ដែលស្មើនឹង ៤៧,៣% នៃចំណាយចរន្តថ្នាក់ជាតិសរុប។ ទោះយ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ មានការកើនឡើង ២០% ជាមធ្យមប្រចាំឆ្នាំ និងមាននិន្នាការកើនឡើងលើសពីផែនការក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រសិនបើនិន្នាការនេះនៅតែបន្ត កំណើនប្រាក់បៀវត្សនឹងក្លាយជាសំពាធសម្រាប់ហិរញ្ញវត្ថុសាធារណៈ។ ដោយគណនីមានការផ្លាស់ប្តូរ ដោយបញ្ចូលផ្នែកខ្លះនៃចំណាយលើបៀវត្សទៅក្នុងការចំណាយលើរបបសន្តិសុខសង្គម និងសោធនិវត្តន៍ អាចធ្វើមានការលំបាកដល់ការវិភាគនូវនិន្នាការរបស់ប្រាក់បៀវត្ស[3][11]។

**ចំណូលពីកាស៊ីណូ៖** ក្រោយពីការប្រកាសបិទល្បែងតាមអនឡាញនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលរំពឹងថា ចំណូលដែលបានមកពីវិស័យដែលពាក់ព័ន្ធនឹងឆ្នោត និងកាស៊ីណូនឹងធ្លាក់ចុះប្រហែល ១១,៧% ធៀបនឹងឆ្នាំមុន[4]។

---

[3] យោងលើ របាយការណ៍សង្ខេបប្រតិបត្តិការថវិការដ្ឋ ប្រចាំខែ (TOFE) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណនីសន្តិសុខសង្គម ត្រូវបានប្តូរទៅជាចំណាយមិនមែនបន្ទុកបុគ្គលិក ចាប់ពីឆ្នាំ២០១៩។

[4] ចំនុចនេះត្រូវបានលើកឡើងក្នុងសេចក្តីថ្លែងហេតុ អំពីសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

**ចំណូលដែលបានមកពីលទ្ធផលនៃការអនុវត្តតាម និងការពង្រឹងច្បាប់អាចនឹងថមថយ៖** ផលចំណេញដែលបានមកពីការពង្រឹងការអនុវត្តតាម និងការពង្រឹងច្បាប់លើការបង់ពន្ធលើប្រាក់ចំណូល និងពន្ធប្រយោលបានធ្វើឱ្យចំណូលថវិកាមានភាពប្រសើរគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែកំណើននេះអាចត្រូវបានគេរំពឹងទុកថា នឹងមានភាពថយចុះនាពេលអនាគត ដោយសារតែចំណូលពីសារពើពន្ធរបស់កម្ពុជាក្នុងពេលបច្ចុប្បន្នធៀបទៅនឹងផ.ស.ស ស្មើ ឬលើសប្រទេសដទៃផ្សេងទៀត ដែលជាប្រទេសមានស្ថានភាពប្រហាក់ប្រហែលនឹងកម្ពុជា។

**ប្រាក់ចំណូលពន្ធពីវិស័យពាណិជ្ជកម្មអន្តរជាតិអាចនឹងធ្លាក់ចុះ៖** ចំណូលពីពន្ធពាណិជ្ជកម្មអន្តរជាតិអាចនឹងធ្លាក់ចុះក្នុងរយៈពេលមធ្យម ដោយសារប្រទេសកម្ពុជាបានធ្វើសមាហរណកម្មពេញលេញទៅក្នុងអាស៊ាន និងប្រឈមនឹងការប្រកួតប្រជែងជាមួយប្រទេសដែលជាសមាជិកអាស៊ានដទៃទៀត។

**ជំនួយឥតសំណង និងការឧបត្ថម្ភធនអាចនឹងធ្លាក់ចុះ៖** ចំណូលពីការផ្តល់ជំនួយឥតសំណង និងការឧបត្ថម្ភធនត្រូវបានគេរំពឹងដែរថានឹងថយចុះ នៅពេលដែលប្រទេសកម្ពុជាមានឋានៈជាប្រទេសមានចំណូលកម្រិតមធ្យម[5][12]។

# ការវិភាគដើម្បីជួយគាំទ្រដល់សមាជិកសភា

## ជម្រើសនៃសេណារីយ៉ូ (ការសន្មត) ក្នុងការធ្វើផែនការ

### ការប្រែប្រួលនៃថវិកាពាក់ព័ន្ធនឹងការសន្មតលើកំណើនចំណាយសម្រាប់បន្ទុកបុគ្គលិក

បន្ទុកបុគ្គលិក (ថ្នាក់ជាតិ) កើនឡើង២១% ជាមធ្យម ដោយយោងតាមទិន្នន័យពីឆ្នាំ២០១៦ទៅ ២០១៨។ អត្រាកំណើននេះខ្ពស់ជាងកំណើនផែនការបច្ចុប្បន្នដែលមានអត្រាត្រឹម ៨,៦% (ទោះបីជាការផ្លាស់ប្តូរគណនី ដោយដកយកចំណាយមួយផ្នែកពីបន្ទុកបុគ្គលិក មកដាក់ក្នុងគណនីចំណាយសម្រាប់របបសន្តិសុខសង្គម ធ្វើឱ្យមានភាពស្មុគស្មាញក្នុងការវិភាគក៏ដោយ)។

ការគណនាសាកល្បងនូវកំណើនចំណាយបន្ទុកបុគ្គលិក ដោយប្រើសេណារីយ៉ូបីផ្សេងគ្នា និងផលប៉ះពាល់ទៅលើតុល្យភាពថវិកាឆ្នាំ២០២០ អាចជាការផ្តល់ព័ត៌មានបន្ថែម ដូចមាននៅក្នុងតារាងទី១២។

សេណារីយ៉ូនីមួយៗ មានផលប៉ះពាល់តិចតួចលើតុល្យភាពថវិកា ដូចខាងក្រោម៖

- សេណារីយ៉ូទី ១ សន្មតថាបៀវត្សនៅឆ្នាំ២០២០ នឹងកើនឡើងស្មើនឹងអត្រាជាមធ្យមរយៈពេល ៣ឆ្នាំចុងក្រោយ(២១%)។ នៅក្នុងសេណារីយ៉ូនេះ ឱនភាពថវិកាសរុប នឹងកើនឡើងចំនួន ៩៨៧ ប៊ីលានរៀល ធៀបទៅនឹងឱនភាពសរុបនៃច្បាប់ថវិកាឆ្នាំ២០២០ ដែលកើនទៅដល់ ៧,៩៨១ ប៊ីលានរៀល។

[5] ជំនួយឥតសំណងអាចថយចុះ និងជំនួសដោយកម្ចីសម្បទាន ខណៈដែលជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានកាត់បន្ថយ ឬទូទាត់ដោយរំលោះប្រាក់កម្ចី។

តារាងទី១២៖ ការប្រៀបធៀបការព្យាករនៃការចំណាយទៅលើបន្ទុកបុគ្គលិក (ប៊ីលានរៀល)

| បន្ទុកបុគ្គលិកនៅថ្នាក់ជាតិ | ថវិកាគ្រោងរបស់រដ្ឋាភិបាលឆ្នាំ ២០២០ | សេណារីយ៉ូទី១ (កំណើនមធ្យមរយៈពេល៣ឆ្នាំ២១%) | សេណារីយ៉ូទី២ (កំណើនទ្វេដង ឆ្នាំ ២០២០ អត្រា ១៧%) | សេណារីយ៉ូទី៣ កំណើនពាក់កណ្តាល ២០២០ អត្រា១៥%) |
|---|---|---|---|---|
| ចំណូលសរុបក្នុង | 24,093 | 24,093 | 24,093 | 24,093 |
| ចំណាយសរុប | 31,096 | 32,074 | 31,772 | 30,758 |
| តុល្យភាពថវិកា | (7,003) | (7,981) | (7,679) | (6,665) |

*ប្រភព៖ច្បាប់ស្តីពីការទូទាត់ថវិកា២០១៥-២០១៨ និងច្បាប់ថវិកា២០១៩-២០២០(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)*

- សេណារីយ៉ូទី២ សន្មតថាប្រាក់បៀវត្សនៅឆ្នាំ២០២០ នឹងកើនឡើងទ្វេដងនៃផែនការថវិកាកំណើន ពោលគឺ១៧% ជំនួសអោយ ៨,៦%។ ជាលទ្ធផលឱនភាពសរុបនៃច្បាប់ថវិកាឆ្នាំ ២០២០ កើនឡើងដល់ ៧ ៦៧៩ ប៊ីលានរៀល ធៀបទៅនឹងឱនភាពដែលបានគ្រោងទុកដែលមានតែ ៧ ០០៣ ប៊ីលានរៀល។
- សេណារីយ៉ូ ៣ សន្មតថាអត្រាកំណើនប្រាក់បៀវត្ស ឆ្នាំ២០២០ កើនឡើងពាក់កណ្តាលនៃការគ្រោងទុក ពោលគឺ ៤,៣% ជំនួសអោយ ៨,៦%។ ក្រោមសេណារីយ៉ូនេះ ឱនភាពសរុបនៃថវិកាឆ្នាំ២០២០ នឹងថយចុះចំនួន ៣៣៨ ប៊ីលានរៀល គឺធ្លាក់មកនៅត្រឹម ៦ ៦៦៥ ប៊ីលានរៀល។

# ថវិកាកែសម្រួល(ផែនការតាមសេណារីយ៉ូអព្យាក្រឹត)

ពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៨ ចំណូលជាក់ស្តែងតែងខ្ពស់ជាងផែនការប្រមាណ១០% ជាមធ្យមក្នុងមួយឆ្នាំៗ ។ ជាមួយគ្នានេះផងដែរ ចំណាយជាក់ស្តែងតែងតែទាបជាងផែនការប្រមាណ ៣% ជាមធ្យមក្នុងមួយឆ្នាំ។

ប្រសិនបើនិន្នាការនេះនៅតែបន្ត ឱនភាពថវិកានឹងរំពឹងថាមានចំនួនប្រមាណ ៣ ២៧៩ ប៊ីលានរៀល ជំនួសឱ្យ ៧ ០០៣ ប៊ីលានរៀល។









# ការប្រៀបធៀបទៅនឹងប្រទេសដែលជាសមាជិកអាស៊ានដទៃទៀត

ការខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូលរបស់ប្រទេសកម្ពុជាទទួលបានលទ្ធផលល្អ ដែលធ្វើឱ្យផលធៀបនៃចំណូលធៀបនឹងផ.ស.ស មានកម្រិតខ្ពស់ (២២,៥% ក្នុងឆ្នាំ២០២០) លើសផលធៀបនៃប្រទេសមួយចំនួនដែលរួមមាន៖ ហ្វីលីពីន១៦,៧%, ថៃ ១៥% និងម៉ាឡេស៊ី ១៥,២% (រូបភាពទី៦)។

រូបភាពទី៦៖ការប្រៀបធៀបទៅនឹងប្រទេសដែលជាសមាជិកអាស៊ាន

ការប្រមូលចំណូល ឆ្នាំ២០១៥-២០២០ (%ផ.ស.ស)




ចំណាយលើវិស័យអាទិភាព (គិតជា%ផ.ស.ស)




ឱនភាព(គិតជា%ផ.ស.ស)




សន្និធិបំណុលជារួម (គិតជា%ផ.ស.ស)




*ប្រភព៖ច្បាប់ថវិកាជាតិ*

ការចំណាយលើវិស័យអាទិភាពមួយចំនួននៅកម្ពុជា លើសពីការចំណាយរបស់អាស៊ានជាមធ្យម ក្នុងវិស័យសុខាភិបាល និងវិស័យការពារជាតិ ប៉ុន្តែទាបជាងនៅក្នុងវិស័យអប់រំ (៣,១% បើធៀបទៅនឹងការចំណាយរបស់អាស៊ាន ៣,២%)។ ទោះជាយ៉ាងណាក៏ដោយ តួលេខខាងលើអាចបង្ហាញអំពីធាតុចូលប៉ុណ្ណោះ មិនអាចបញ្ជាក់ពីលទ្ធផលឡើយ។

កម្ពុជារំពឹងថាឱនភាពរបស់ខ្លួននឹងមានចំនួន ៥,៩% នៃផ.ស.ស នៅឆ្នាំ២០២០ ដែលខ្ពស់ជាងមធ្យមភាគអាស៊ានទ្វេដង។ ទោះយ៉ាងណា បំណុលជាតិរបស់កម្ពុជាស្ថិតក្នុងចំណោមបំណុលទាបបំផុតនៅក្នុងតំបន់ និងទាបជាងអាស៊ានជាមធ្យមដែលមានប្រមាន ៤៦,៥ ភាគរយនៃ ផ.ស.ស។

# ចំនុចពិភាក្សាបន្ថែមមួយចំនួន សម្រាប់សមាជិកសភា

ចំណុចមួយចំនួនដូចខាងក្រោម អាចជាចំណុចពិចារណាបន្ថែមជូនសមាជិកសភា សម្រាប់លើកឡើងនៅក្នុងកិច្ចការពិភាក្សាជុំវិញសេចក្តីព្រាងច្បាប់ថវិកាជាតិ ឆ្នាំ២០២០៖

- ការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងការវិនិយោគមូលធន អាចគួរតែមានការវិភាគបន្ថែមទៀតចំពោះគម្រោងជាក់លាក់ដែលពាក់ព័ន្ធក្នុងការវិនិយោគមូលធននេះ ដើម្បីជួយសម្រេចឱ្យបាននូវគោលដៅកម្មវិធីវិនិយោគរបស់រាជរដ្ឋាភិបាល (២០២០-២០២២)។
- មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)បានផ្តល់អនុសាសន៍ថា ប្រទេសកម្ពុជាគួរពិនិត្យមើលប្រព័ន្ធពន្ធរបស់ខ្លួន ដើម្បីប្រមូលចំណូលពន្ធពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច (E-commerce activity) ជាពិសេសទៅលើពន្ធអាករលើតម្លៃបន្ថែម (IMF ,២០១៨)។
- ធនាគារពិភពលោកបានផ្តល់អនុសាសន៍ថា កម្ពុជាគួរពិនិត្យឡើងវិញនូវប្រព័ន្ធពន្ធលើអចលនទ្រព្យ ជាមួយនឹងការតម្លើងអត្រាការប្រាក់ និងវាយតម្លៃឡើងវិញនូវតម្លៃអចលនទ្រព្យយ៉ាងតិចរៀងរាល់៥ឆ្នាំម្តង(World Bank, ២០១៩)។
- ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ កម្រិតប្រាក់បៀវត្សជាប់ពន្ធត្រូវបានផ្លាស់ប្តូរជារៀងរាល់ឆ្នាំ ដើម្បីឆ្លើយតបទៅនឹងអតិផរណា។ ប្រសិនបើរាជរដ្ឋាភិបាលមានបំណងកែសម្រួលជាប្រចាំដូចនេះ ការពិនិត្យ និងដាក់ចេញនូវគោលនយោបាយដែលមានលក្ខណៈអចិន្ត្រៃយ៍អាចជាការល្អប្រសើរដើម្បីបង្កើតជាយន្តការ (ឧទាហរណ៍ ដូចជាពឹងផ្អែកលើសន្ទស្សន៍អត្រាអតិផរណាពីឆ្នាំមុន) ដើម្បីផ្តល់ដល់និយោជិត និងនិយោជកនូវភាពជាក់លាក់ក្នុងការរៀបចំផែនការចំណាយនៅក្នុងធុរៈកិច្ច និងការប្រើប្រាស់របស់ពួកគេ សម្រាប់ឆ្នាំខាងមុខ។

# ឯកសារយោង


1. RGC, (2019). *Draft Law on financial management 2020.* Phnom Penh, Cambodia: Royal Government of Cambodia.
2. MoEF (2019). Law on Financial Management 2019. Phnom Penh, Cambodia: Ministry of Economy and Finance.
3. RGC (2015-2017). Law on National Budget Settlement 2015, 2016, and 2017. Phnom Penh, Cambodia: Royal Government of Cambodia.
4. RGC, (2019). *Statement of reason. Draft Law on Financial Management 2020*. Phnom Penh, Cambodia: Royal Government of Cambodia.
5. ADB. (2019). *Asian Development Outlook 2019. Update. Fostering growth and inclusion in Asia's cities* [Online]. Manila, Philippines Asian Development Bank. Available at: https://www.adb.org/publications/series/asian-development-outlook 2019].
6. World Bank, (2019). *Cambodia Economic update. Recent economic development and outlook.* [2019] Phnom Penh, Cambodia, Available at: http://documents.worldbank.org/curated/en/843251556908260855/pdf/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook.pdf.
7. IMF. (2018). *Cambodia : 2018 Article IV Consultation-Press Release; Staff Report; Staff Statement; and Statement by the Executive Director for Cambodia* [Online]. IMF. Available at: https://www.imf.org/en/Publications/CR/Issues/2018/12/17/Cambodia-2018-Article-IV-Consultation-Press-Release-Staff-Report-Staff-Statement-and-46478 2019].
8. MEF, (2019). *The draft of macroeonomic policy framework and public financial framework for preparing the draft law on financial management 2020*. Phnom Penh, Cambodia Minstry of Eonomy and Fianance.
9. NIS, (2017). *Population Projection of Cambodia 2013-2023.* Phnom Penh: MoP, Available at: http://hismohcambodia.org/public/fileupload/PopulationProjection_2023.pdf [Accessed 2 Aug 2018].
10. MoEF, (2017-2019). *Cambodia Public Debt Statistic Bullentin.* . Phnom Penh, Cambodia.
11. MEF, (2019). *Statement Budget Impementation in September 2019.* Phonm Penh, Available at: https://www.mef.gov.kh/documents/shares/publication/tofe/TOFE-September-2019-EN.pdf [Accessed 15 November 2020].
12. Council for the Development of Cambodia, (2017). *Cambodia Development Finance Assessment.* . Phnom Pennh: Cambodia Rehabilitation & Development Board (CRDB) CDC, Available at: http://www.cdc-crdb.gov.kh/cdc/twg_network/twg_network_february_2017/documents/session_7_dfa.pdf [Accessed 15 November 2020].

# ឧបសម្ព័ន្ធ

តារាងA៖ សង្ខេបចំណាយចរន្តតាមក្រសួង ស្ថាប័ន (២០១៦-២០២០)

| ចំណាយចរន្តតាមក្រសួង ស្ថាប័ន | ភាគរយនៃចំណាយចរន្តសុរប (%) | | | | | កំណើន | កំណើនមធ្យម |
|---|---|---|---|---|---|---|---|
| | **2016** | **2017** | **2018** | **2019** | **2020** | 2020 | 2016-2020 |
| ក្រសួងអប់រំ យុវជន និងកីឡា | 17.0% | 17.1% | 17.9% | 17.5% | 17.8% | 8.7% | 16.7% |
| ក្រសួងការពារជាតិ | 14.9% | 14.4% | 14.9% | 14.4% | 14.1% | 5.0% | 14.0% |
| ក្រសួងមហាផ្ទៃ | 10.6% | 10.5% | 10.9% | 10.1% | 10.9% | 15.4% | 8.9% |
| ក្រសួងសុខាភិបាល | 9.7% | 8.9% | 9.2% | 9.2% | 9.1% | 5.9% | 11.3% |
| ក្រ.សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 6.3% | 6.0% | 6.0% | 5.9% | 6.3% | 14.5% | 13.7% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 5.3% | 7.0% | 5.4% | 4.7% | 4.9% | 11.3% | 20.4% |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 5.2% | 5.0% | 3.9% | 2.5% | 2.4% | 2.8% | 3.8% |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 3.5% | 2.9% | 2.6% | 2.4% | 2.3% | -0.6% | 4.1% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1.6% | 1.6% | 1.6% | 1.6% | 1.6% | 6.9% | 13.8% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1.5% | 1.7% | 2.0% | 1.4% | 1.5% | 14.3% | 21.0% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 1.3% | 1.2% | 1.1% | 1.1% | 1.1% | 7.3% | 10.2% |
| រដ្ឋសភា | 1.3% | 1.2% | 1.2% | 1.1% | 1.1% | 5.5% | 7.5% |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 0.6% | 1.1% | 1.5% | 1.1% | 1.0% | 2.8% | 37.2% |
| ក្រសួងយុត្តិធម៌ | 0.8% | 0.8% | 0.9% | 0.9% | 0.9% | 9.8% | 21.3% |
| ក្រសួងធនធានទឹក និងឧត្តុនិយម | 0.8% | 0.9% | 0.9% | 0.9% | 0.9% | 3.0% | 17.3% |
| ក្រ.ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 0.8% | 0.9% | 0.8% | 0.9% | 0.9% | 3.8% | 15.3% |
| ក្រ.រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 1.0% | 1.1% | 1.1% | 1.0% | 0.8% | -15.8% | 10.2% |
| ក្រសួងពាណិជ្ជកម្ម | 1.1% | 1.0% | 1.0% | 0.9% | 0.7% | -14.6% | 2.1% |
| ក្រសួងទេសចរណ៍ | 0.6% | 0.6% | 0.6% | 0.6% | 0.6% | 5.0% | 15.8% |
| ព្រះបរមរាជវាំង | 0.7% | 0.8% | 0.6% | 0.6% | 0.6% | 4.5% | 6.7% |
| ក្រសួងផែនការ | 0.5% | 0.5% | 0.5% | 0.5% | 0.5% | 6.7% | 17.8% |
| ក្រសួងបរិស្ថាន | 0.5% | 0.5% | 0.6% | 0.5% | 0.5% | 6.7% | 20.1% |
| ក្រសួងព័ត៌មាន | 0.5% | 0.5% | 0.5% | 0.5% | 0.5% | 5.9% | 12.6% |
| ព្រឹទ្ធសភា | 0.6% | 0.5% | 0.5% | 0.5% | 0.5% | 0.1% | 9.1% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 0.5% | 0.7% | 0.5% | 0.4% | 0.4% | 7.6% | 16.7% |
| ក្រសួងធនធានរ៉ែ និងថាមពល | 0.3% | 0.4% | 0.3% | 0.3% | 0.4% | 30.8% | 31.8% |
| ក្រសួងធម្មការ និងសាសនា | 0.4% | 0.4% | 0.4% | 0.4% | 0.4% | 6.9% | 19.1% |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | 0.8% | 1.2% | 1.2% | 0.5% | 0.4% | -18.3% | 140.5% |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 0.3% | 0.3% | 0.3% | 0.3% | 0.3% | 9.2% | 18.7% |
| ក្រសួងមុខងារសាធារណៈ | 0.3% | 0.3% | 0.3% | 0.3% | 0.3% | 14.4% | 17.2% |
| រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 0.5% | 0.4% | 0.4% | 0.3% | 0.3% | 7.8% | -2.3% |
| ក្រសួងកិច្ចការនារី | 0.3% | 0.3% | 0.3% | 0.3% | 0.3% | 8.6% | 12.3% |
| អង្គភាពប្រឆាំងអំពើពុករលួយ | 0.3% | 0.3% | 0.3% | 0.3% | 0.3% | 8.2% | 15.3% |
| ក្រ.ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 0.3% | 0.3% | 0.3% | 0.2% | 0.2% | 6.4% | 14.4% |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) | 0.1% | 0.1% | 0.1% | 0.1% | 0.1% | 5.0% | 12.4% |
| អាជ្ញាធរសវនកម្មជាតិ | 0.1% | 0.1% | 0.1% | 0.1% | 0.1% | 0.5% | 10.6% |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 0.1% | 0.1% | 0.1% | 0.1% | 0.1% | 18.9% | 13.1% |

*ប្រភព៖ ច្បាប់ទូទាត់ថវិកាជាតិឆ្នាំ២០១៥-២០១៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩-២០២០*